ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# មតិសំណេះសំណាល
# លោកជំទាវ ជា សិរី ថ្លែងក្នុងឱកាសចូលកាន់តំណែង
# ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ នៅសាលប្រជុំស្ទឹងបរិបូរណ៍ អគារសែនសុខ

សូមគោរព

- ឯកឧត្តមបណ្ឌិត ជា ចាន់តូ ទេសាភិបាលកិត្តិយស ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនាងកញ្ញា ជាថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់!

ថ្ងៃនេះ គឺជាថ្ងៃមួយដ៏មហោឡារិក ប្រកបដោយមនោសញ្ចេតនារំភើបរីករាយ និងកិត្តិយសដ៏ឧត្តុង្គឧត្តមជាទីបំផុត ដែលខ្ញុំម្ចាស់នាងខ្ញុំបានទទួលការប្រោសព្រះរាជទានពី **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** តែងតាំងជា **អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា** តាមការស្នើពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានផ្តល់សេចក្តីទុកចិត្តមកលើរូបនាងខ្ញុំ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ជាបឋម ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងការគោរពដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានស្នើប្រគល់ភារកិច្ចដ៏ឧត្តុង្គឧត្តម និងបេសកកម្មដ៏មានសារៈសំខាន់នេះ និងសូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត ជា ចាន់តូ** ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា ដែលបានដឹកនាំធនាគារជាតិនៃកម្ពុជាប្រកបដោយភាពរីកចម្រើនរុងរឿងនាពេលកន្លងមក។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំក៏សូមថ្លែងអំណរគុណ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ផងដែរ ចំពោះវត្តមានរបស់គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញចូលរួមក្នុងកម្មវិធីថ្ងៃនេះ។

ដើម្បីឆ្លើយតបនឹងទំនុកចិត្តនេះ ខ្ញុំនឹងខិតខំអនុវត្តភារកិច្ចដ៏ឧត្តុង្គឧត្តមនេះ ដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយថ្នាក់ដឹកនាំគ្រប់វិស័យ និងគ្រប់លំដាប់ថ្នាក់ ក៏ដូចជាមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ប្រកបដោយស្មារតីប្រុងប្រយ័ត្ន និងការទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមអភិវឌ្ឍមាតុភូមិយើងឱ្យមានការរីកចម្រើនជាបន្តបន្ទាប់ទៀត។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ការងារអ្វីក៏ដោយទោះបីជាមានការលំបាកស្មុគស្មាញ និងទំហំធំធេងយ៉ាងណាក្តី ក៏គង់តែសម្រេចបានដោយជោគជ័យ ប្រសិនបើយើងទាំងអស់គ្នាចេះរួបរួមគ្នា មានសាមគ្គីភាពជាធ្លុងមួយ មិនមើលបំណាំគ្នា ជួយរែកពន់ភារកិច្ចគ្នា ប្រកបដោយស្មារតីសហការគ្នាយ៉ាងជិតស្និទ្ធ និងការទទួលខុសត្រូវខ្ពស់។ ដូចសុភាសិតមួយបានពោល ថា *"សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់"*។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមចែករំលែកនូវបទពិសោធន៍នៃការសិក្សា និងការងាររបស់ខ្ញុំដូចតទៅ៖

ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីប្រទេសនូវែលសេឡង់ និងចក្រភពអង់គ្លេសលើជំនាញហិរញ្ញវត្ថុនិងធនាគារ ទន្ទឹមនេះខ្ញុំក៏ធ្លាប់ជានិស្សិតជាន់ខ្ពស់ជំនាន់ទី១ នៅសាលាគោលនយោបាយសាធារណៈលីក្វាន់យូផងដែរ។ នៅក្នុងអំឡុងពេលបំពេញការងាររូបខ្ញុំក៏មិនដែលបោះបង់ចោលការសិក្សានោះឡើយ ខ្ញុំនៅតែបន្តរៀនសូត្រជាប្រចាំរហូតទទួលបានសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ច (Ph.D) ពីសាកលវិទ្យាល័យ Adelaide នៃប្រទេសអូស្ត្រាលី នៅឆ្នាំ២០២១។

ចំពោះបទពិសោធន៍ការងារវិញ ខ្ញុំបានចាប់ផ្តើមបម្រើការងារដំបូង នៅធនាគារជាតិនៃកម្ពុជា នៅឆ្នាំ១៩៩៩ ជាមន្ត្រីដ៏វ័យក្មេងមួយរូបនៅឱទ្ទកាល័យ មុននឹងចូលរួមបំពេញការងារនៅនាយកដ្ឋានត្រួតពិនិត្យ។ ដោយសារការខិតខំព្យាយាមបង្កើនចំណេះដឹងសមត្ថភាព និងការយកចិត្តទុកដាក់បំពេញការងារ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ខ្ញុំត្រូវបានប្រគល់ភារកិច្ចជាបន្តបន្ទាប់ រហូតទទួលបានតំណែងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានត្រួតពិនិត្យ និងត្រូវបានផ្តល់សេចក្តីទុកចិត្តឱ្យកាន់មុខតំណែង ជាអគ្គនាយកបច្ចេកទេសតាំងពីឆ្នាំ២០១៣មក ដែលមាននាយកដ្ឋានចំនួន ៥ នៅក្រោមឱវាទ

រួមមាន៖ ១/- នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ២/- នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ៣/- នាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ ៤/- នាយកដ្ឋានស្ថិតិ និង ៥/- នាយកដ្ឋានប្រតិបត្តិការ។

រីឯនវានុវត្តន៍ហិរញ្ញវត្ថុ ខ្ញុំធ្លាប់បានចូលរួមក្នុងក្រុមវិនិច្ឆ័យនៅក្នុង G20 Tech Sprint Initiative ដែលរៀបចំដោយ Saudi G20 Presidency និង BIS Innovation Hub និងថ្មីៗនេះត្រូវបានអញ្ជើញដោយ The Asian Venture Philanthropy Network (AVPN) ឱ្យចូលជាសមាជិកបណ្តាញនៃអ្នកដឹកនាំឈានមុខគេ ក្នុងការជំរុញការផ្លាស់ប្តូរសំខាន់ៗនៅក្នុងតំបន់ ។

ចំពោះការចូលរួមក្នុងឆាកអន្តរជាតិ ខ្ញុំមានតួនាទីជាសមាជិកក្រុមប្រឹក្សា ជាទីប្រឹក្សា និងជាគណៈកម្មាធិការអន្តរជាតិជាច្រើន ដូចជា សមាជិកក្រុមប្រឹក្សានៃវិទ្យាស្ថាន Global Fintech, សមាជិកនៃសម្ព័ន្ធអភិបាលកិច្ចរូបិយប័ណ្ណឌីជីថលរបស់ World Economic Forum, ជាទីប្រឹក្សានៃក្រុមប្រឹក្សាភិបាលបណ្តាញនវានុវត្តន៍ហិរញ្ញវត្ថុអាស៊ាន (AFIN), ជាគណៈកម្មាធិការប្រឹក្សានៃការទូទាត់ឌីជីថលសម្រាប់គម្រោងពាណិជ្ជកម្ម, ជាសមាជិកនៃគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុជាន់ខ្ពស់របស់ស្ត្រី និងយេនឌ័រ (GWFIC) នៃសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) ក្នុងអាណត្តិឆ្នាំ២០១៦-២០១៨ ហើយសហព័ន្ធ AFI បានស្នើ និងទទួលបានការយល់ព្រម ដើម្បីតែងតាំងរូបខ្ញុំ ជាសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិឆ្នាំ២០២៣-២០២៥ បន្តទៀតផងដែរ។

ចំពោះភាពជាអ្នកដឹកនាំក្នុងឆាកអន្តរជាតិ ខ្ញុំក៏ធ្លាប់ជាសមាជិកនៃអ្នកដឹកនាំសកលវ័យក្មេងប្រចាំឆ្នាំ២០១៩ របស់វេទិកាសេដ្ឋកិច្ចពិភពលោក (WEF) ដែលជាវេទិកានៃអ្នកដឹកនាំសកលវ័យក្មេង និងជាសមាជិកអ្នកដឹកនាំវ័យក្មេងរបស់ Asia Society Class ឆ្នាំ២០១៧។

ខ្ញុំតែងប្រកាន់ភ្ជាប់នូវគំនិតសុទិដ្ឋិនិយមថា ការខិតខំប្រឹងប្រែងព្យាយាមដុះខាត់ចំណេះដឹង តាំងពីថ្នាក់តូចរហូតមក រួមជាមួយនឹងការខិតខំព្យាយាមអនុវត្តការងារប្រកបដោយភាពប្រុងប្រយ័ត្ន និងការទទួលខុសត្រូវខ្ពស់ តែងតែនាំឱ្យយើងសម្រេចបានជោគជ័យនូវគោលដៅរបស់យើង ដូចនឹងសមិទ្ធផលដែលខ្ញុំទទួលបានដូចសព្វថ្ងៃនេះ។ ដូច្នេះ ខ្ញុំសូមលើកទឹកចិត្ត និងក្រើនរំលឹកដល់បងប្អូនទាំងអស់គ្នា ត្រូវបង្កើនសមត្ថភាព

រៀនសូត្រជាប្រចាំ ត្រូវខិតខំបំពេញការងារដោយស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ និងមិនត្រូវអស់សង្ឃឹម ឬបោះបង់ភារកិច្ច នៅពេលជួបឧបសគ្គឡើយ។ ដូចសុភាសិតមួយបានពោលថា *"តក់ៗពេញបំពង់"*។

- **គណៈអធិបតី ជាទីគោរព**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់**

ក្រៅពីការអភិវឌ្ឍសមត្ថភាពជាប្រចាំ និងការខិតខំបំពេញមុខងារភារកិច្ចរបស់ខ្លួន យើងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីនិន្នាការសកលលោក ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស និងមានភាពមិនច្បាស់លាស់ និងការជះឥទ្ធិពលនៃកត្តាខាងក្រៅនេះមកលើស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជា។ ជាក់ស្តែង នៅឆ្នាំ២០២២ សេដ្ឋកិច្ចពិភពលោកមានកំណើនយឺតត្រឹម ៣,៤% ដោយសារបញ្ហាជម្លោះរុស្ស៊ី-អ៊ុយក្រែន នាំឱ្យអតិផរណាកើនឡើងខ្ពស់ និងការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ។ ស្ថិតក្នុងបរិបទនេះ សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០២២នេះ បានបន្តងើបឡើងជាមួយការបើកប្រទេសឡើងវិញ កំណើនតម្រូវការខាងក្នុង និងខាងក្រៅដែលបានគាំទ្រដល់កំណើនសកម្មភាពក្នុងស្រុក និងការបន្តវិធានការបន្ធូរបន្ថយការរឹតត្បិតចំពោះជំងឺកូវីដ-១៩ មានដូចជា ១/-ការបន្ធូរបន្ថយបទប្បញ្ញត្តិម៉ាក្រូ និងមីក្រូប្រុងប្រយ័ត្នមួយចំនួន ២/-ការរៀបចំឥណទានឡើងវិញ ការបន្ធូរបន្ថយ ឬលើកលែងការយកសោហ៊ុយ ឬការពិន័យផ្សេងៗតាមស្ថានភាពជាក់ស្តែងរបស់អតិថិជន។ ជាក់ស្តែង ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២២ បន្តមានភាពរឹងមាំ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចប្រសើរជាងមុនក្នុងអត្រា៥,២% អត្រាអតិផរណា៥,៤% និងមានស្ថិរភាពអត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់ ៤.១០២ រៀលក្នុងមួយដុល្លារអាមេរិក។ រីឯ ទុនបម្រុងអន្តរជាតិបន្តរក្សាបានក្នុងកម្រិតសមស្រប ដែលអាចធានាការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បាន ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍគួរមាន។

ស្ថិរភាពល្អប្រសើរនៃម៉ាក្រូសេដ្ឋកិច្ច បានផ្តល់អំណោយផលដល់ការរីកចម្រើនឥតឈប់ឈរនៃវិស័យធនាគារ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏បន្តមានស្ថានភាពរឹងមាំ ដែលការណ៍នេះបានរួមចំណែកគាំទ្រដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចផងដែរ។ ការរីកចម្រើននៃវិស័យធនាគារបានឆ្លុះបញ្ចាំង តាមរយៈទ្រព្យសកម្មក្នុងប្រព័ន្ធ

ធនាគារដែលកើនឡើងដល់ ២៨៩,៤% នៃផ.ស.ស, ឥណទាន និងប្រាក់បញ្ញើចំពោះអតិថិជនកើនឡើងដល់ ១៩៩% និង ១៦១,២% នៃផ.ស.ស រៀងគ្នា។ ចំពោះភាពរឹងមាំនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបញ្ជាក់ឱ្យឃើញ តាមរយៈកំណើនទាបនៃឥណទានមិនដំណើរការដែលមានអត្រាពី ២,១% ទៅ ២,៩% ទោះបីជាយើងបានបញ្ចប់វិធានការបន្ធូរបន្ថយបទប្បញ្ញត្តិក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ។ សន្ទនីយភាព និងសាធនភាពបន្តមានកម្រិតខ្ពស់ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ដូចជាប្រព័ន្ធធនាគារទាំងមូលអាចឆ្លើយតបនឹងតម្រូវការសាច់ប្រាក់របស់អតិថិជនបានគ្រប់គ្រាន់និងគ្រប់គ្រងហានិភ័យយ៉ាងមានប្រសិទ្ធភាព។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់អេឡិចត្រូនិកឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ ដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការ ការរីកចម្រើនបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់ និងសកលលោក។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តពង្រឹងក្របខណ្ឌបទប្បញ្ញត្តិ វិធាននិងនីតិវិធី ដើម្បីសម្រេចឱ្យបានការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជា សេវាធនាគារអេឡិចត្រូនិក និងធនាគារចល័ត ព្រមទាំងគាំទ្រដល់ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់រវាងកម្ពុជាជាមួយនឹងប្រទេសដទៃ នៅក្នុងតំបន់និងទូទាំងសកលលោក។ លើសពីនេះ បរិយាបន្នហិរញ្ញវត្ថុក៏ត្រូវបានយកចិត្តទុកដាក់ និងលើកកម្ពស់យ៉ាងសកម្ម តាមរយៈការលើកទឹកចិត្តដល់ការពង្រីកសេវាធនាគារដែលមានកម្រៃសេវាសមរម្យ ដល់ទីជនបទ។

ជាក់ស្តែង ភារកិច្ចចំពោះមុខរបស់យើងមានទំហំធំធេងណាស់ ដូច្នេះ យើងត្រូវបន្តអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងរូបិយវត្ថុ ឱ្យស្របតាមគោលនយោបាយដែលដាក់ចេញដោយរាជរដ្ឋាភិបាល។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមប្តេជ្ញាចិត្តថា៖

- បន្តរក្សានូវសមិទ្ធផលដែលមានស្រាប់ និងចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារ និងកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

- បង្កើតឱ្យមានសមិទ្ធផលថ្មីៗជាច្រើនបន្ថែមទៀតក្នុងប្រព័ន្ធធនាគារ និងបង្កើន ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិផ្សេងៗទៀត ដែលនឹងបម្រើជា ប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិ និងប្រជាជនកម្ពុជា និង
- បន្តរក្សា និងពង្រឹងសាមគ្គីភាពផ្ទៃក្នុងឱ្យបានរឹងមាំ ជាមួយថ្នាក់ដឹកនាំ និង មន្ត្រីបុគ្គលិកទាំងអស់ សហការគ្នា និងចូលរួមគ្រប់សកម្មភាពដែលផ្តល់ផល ប្រយោជន៍ដល់ស្ថាប័ន និងប្រទេសជាតិ។

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់**

ផ្លូវដែលយើងត្រូវដើរជាបន្តទៀត គឺនៅវែងឆ្ងាយ ត្រូវឆ្លងកាត់ការលំបាក និង ភាពស្មុគស្មាញជាច្រើនរាប់មិនអស់ថែមទៀត ប៉ុន្តែខ្ញុំសង្ឃឹមថា បើយើងមានសាមគ្គីភាពល្អ មានគោលជំហរ និងស្មារតីសហការគ្នាល្អ មានការប្តេជ្ញាចិត្តម៉ឺងម៉ាត់ ខិតខំប្រឹងប្រែងរួមគ្នា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលដែលមាន ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** ជាអ្នកដឹកនាំនោះ យើងនឹងសម្រេចកិច្ចការទាំងអស់នោះបានដោយ ជោគជ័យ។ ផ្ទុយទៅវិញ ទោះបីការងារនោះតូចតាចប៉ុណ្ណាក្តី បើយើងគ្មានសាមគ្គីភាព គ្មានកិច្ចសហការ មិនរៀនសូត្រពីគ្នាទៅវិញទៅមក មិនអធ្យាស្រ័យគ្នា មិនរួមគ្នាវែកពន់ ហើយប្រមាថការងារ នោះយើងនឹងមិនអាចសម្រេចជោគជ័យដ៏ត្រចះត្រចង់បាន ជាដាច់ខាត។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ សូមជួបប្រទះ តែពុទ្ធពរទាំង ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**